**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ២៥២
ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០២
**សាលដីកា**
លេខៈ ២១
ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម .......... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ............ ជាចៅក្រម
៤-លោក ....... ជាចៅក្រម
៥-លោក ........ ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក ..............

**តំណាងមហាអយ្យការ**
-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្ដឹងសាទុក្ខពីសាលដីកា ១៥៤(ឈ) ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០០១នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥២១ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ គសសវជាចុងបណ្ដឹងសាទុក្ខ ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ របរកស៊ី ប្រធានមន្ទីរទេសចរណ៏ខេត្តសៀមរាប មានទីលំនៅ ផ្ទះលេខ ៦០០ ភូមិវត្តបូព៌ ឃុំសាលាកំរើក ស្រុកសៀមរាប ខេត្តសៀមរាប ដែលតំណាងដោយលោក សយ។

និង ចុងចម្លើយឈ្មោះផឆឡជម្ចាស់បណ្ដឹងសាទុក្ខ ភេទប្រុស អាយុ៣០ឆ្នាំជាតិខ្មែរ របរកស៊ីប្រធានសាខាធនាគារសន្តិភាពពាណិជ្ជចំកាត់ ឪពុកឈ្មោះផៃ អៀង "រ" ម្ដាយឈ្មោះ ហូ គី"ស" ។

***កម្មវត្ថុបណ្ដឹងៈ*** ប្ដឹងទាមទារសំណងជាប្រាក់ ។

បានឃើញ បណ្ដឹងសាទុក្ខលេខ ២៣៣ ចុះថ្ងៃទី១៨ខែធ្នូឆ្នាំ២០០១ របស់ឈ្មោះ ឡាំង គឹមសេង បានប្ដឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៏ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេលីលេខ ២៥២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០២ របស់ តុលាការកំពូល ។
តាមពាក្យបណ្ដឹងរបស់ឈ្មោះ គសសវចុះថ្ងៃទី២៤-៤-២០០០ បានប្ដឹងទាមទារ សំណងជាប្រាក់ដុល្លាអាមេរិកសរុបទាំងអស់ចំនួន ២១០.៥៩០ ដុល្លាអាមេរិក ដោយសំអាងហេតុថា កាលពី ថ្ងៃទី០៥-០៥-១៩៩៧ ខ្លួនបានយកប្រាក់ចំនួន ១០០.០០០ ដុល្លាអាមេរិក និង នៅថ្ងៃទី០៧-០៥-១៩៩៧ បានយកប្រាក់ចំនួន ២០០.០០០ដុល្លាអាមេរិក ទៀតទៅផ្ញើនៅធនាគារសន្តិភាពពាណិជ្ជចំកាត់ ខេត្តសៀមរាប លុះដល់កាលបរិច្ឆេទមួយឆ្នាំខ្លួនបានដកប្រាក់ជាបន្តបន្ទាប់ ដោយ

មានការលំបាកជាខ្លាំង លុះដល់ថ្ងៃចុងក្រោយ ថ្ងៃទី២១-០៤-២០០០ ចំនួនទឹកប្រាក់ដើមនៅសល់ ១៨៩.៧២១ ដុល្លាអាមេរិក ដោយមិនទាន់គិតការប្រាក់ ១១% គិតពីថ្ងៃទី០៥-០៥-១៩៩៩ មកឥឡូវនេះខ្លួនបើកប្រាក់នោះមិនបានទើបប្តឹងចូលមកតុលាការ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៣៤ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០១ របស់ តុលាការ ខេត្តសៀមរាប ឧត្តរមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេច ដូចតទៅៈ

១ - ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៤-០៤-២០០០ របស់ដើមចោទឈ្មោះ គសសវទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២ - ទទួលលិខិតផ្ទេរសិទ្ធិរបស់លោក គសសវទៅឱ្យប្រពន្ធឈ្មោះ ខផល ចុះថ្ងៃទី០៨-០៦-២០០០ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៣ - បង្គាប់ឱ្យធនាគារសន្តិភាពពាណិជ្ជចំកាត់ សាខាខេត្តសៀមរាបដែលមានឈ្មោះ តដនជានាយក និង ឈ្មោះ ផធឡជាប្រធានសាខាប្រចាំខេត្តសៀមរាប សងប្រាក់ដើមចំនួន ២០១.៥៣៤ .៧០សេន(ម្ភៃម៉ឺនមួយពាន់ប្រាំរយសាមសិបបួនដុល្លាអាមេរិក និង ចិតសិប សេន )និង ការប្រាក់ ១១%ក្នុងមួយឆ្នាំ គិតពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០០ រហូតដល់សងប្រាក់គ្រប់ចំនួនទៅឱ្យដើមចោទ ។

៤- បង្គាប់ឱ្យធនាគារសន្តិភាពពាណិជ្ជចំកាត់ ដែលមានឈ្មោះ តដនជានាយក និង ឈ្មោះ ផធឡ ជាប្រធានសាខាសងសំណងជម្ងឺចិត្តចំនួន ៣០.០០០ដុល្លា"បីម៉ឺនដុល្លាសហរដ្ឋអាមេរិកគត់ ) ឱ្យទៅអ្នកស្រី ខផលសុំលើសពីនេះលើកចោល ។

៥ - បើពុំមានប្រាក់សងទេសម្រេច រឹបអូសទ្រព្យសម្បត្តិ និង ធនាគារសន្តិភាពពាណិជ្ជាចំកាត់ ដែល មានពីរជាន់ មានទីតាំងស្ថិតនៅ ភូមិមណ្ឌល១ ឃុំស្វាដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប របស់ឈ្មោះ តដននិង ឈ្មោះ ផៃ ឆេងឡាយ ដើម្បីលក់ឡាយឡុងជានាសំណង ។

៦- សម្រេចដាក់គុកបង្ខំរូបកាយឈ្មោះ តដននិងឈ្មោះផធឡក្នុងករណីធនាគារពុំមានទ្រព្យសម្បត្តិលក់ឡាយឡុងទេ តាមមាត្រា១៣៣ នៃច្បាប់ស្តីពី នីតិវិធីអនុវត្តសាលក្រម ។

៧ - បង្គាប់ឱ្យធនាគារសន្តិភាពពាណិជ្ជចំកាត់សាខា ខេត្តសៀមរាប ដែមានឈ្មោះ តដនជានាយក និង ឈ្មោះ ផធឡជាប្រធានសាខា បង់ប្រាក់ប្រដាប់ក្តី គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ១.៨០០រៀល រង្វាន់ ក្រឡាបញ្ជីកាន់បីបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោន ៥.០០០៛ សរុប៧.០០០៛ ដែលដើមចោទបង់រួចជាស្រេច ។ កាលបើផុតឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់នេះទៅ ដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រមួយភាគរយ លើទឹកប្រាក់ដែលត្រូវសងទៅដើមចោទ ប្រាក់ពន្ធសមា មាត្រនេះត្រូវបង់ចូលថវិការដ្ឋ៨០ភាគរយ រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយ ។ ពន្ធសមាមាត្រនេះ បង្គាប់ឱ្យដើមចោទបង់ទុកជាមុន ទើបឱ្យចុងចម្លើយសងវិញជាក្រោយ ។

៨- សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ខែមិថុនាឆ្នាំ២០០១របស់ឈ្មោះ ឡគស បានប្តឹងមិនសុខចិត្ត នឹងសាល

ក្រមលេខៈ០៣៤ ចុះថ្ងៃទី០៩-០៣-២០០១ របស់ តុលាការ ខេត្ត សៀមរាប ត្រង់ចំណុចនៃសេចក្ដីសម្រេច ទាំងមូល។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ ១៥៤ (ឈ) ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេច ដូចតទៅៈ

១ - ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២០-០៦-២០០១ របស់លោកមេធាវី ឡូគស ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២ - បដិសេធចំណុចទី០៦នៃសេចក្ដីសម្រេច របស់សាលក្រមរដ្ឋប្បវេណីលេខ ៣៤ ចុះថ្ងៃទី០៩-០៣-២០០១ របស់តុលាការខេត្តសៀមរាប-ឧត្តមានជ័យ ចោលជាអសារបង់ ។ ចំណុចក្រៅពីនេះរក្សាទុកជា បានការដដែល ។

៣ - កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣០០០រៀល ដែលដើមបណ្ដឹងបានបង់រួចហើយ គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្នឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោន ៥.០០០៛ ចំណាយលើអាផ្ញាធរតុលាការ ៥.០០០០៛ សរុប ១៣.០០០៛ ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវី ............តំណាង ឱ្យដើមចោទកំបាំង មុខចុងម្លើយ បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងសាទុក្ខលេខ ២៣៣ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ របស់ឈ្មោះ ឡូគស បានប្ដឹងមិនសុខចិត្ត នឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសម្រេច ទាំងមូល ។

បានឃើញ លិខិតបង្គាប់ឱ្យឈ្មោះ ផធឡធ្វើសារណាការពារ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៣ តែឈ្មោះនេះមិន បានធ្វើសារណាការពារជូនមកតាមការកំណត់របស់តុលាការកំពូល ទេ ។

បានស្ដាប់របាយការណ៍របស់ចៅក្រុមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា

បណ្ដឹងសាទុក្ខរបស់មេធាវីលោក ឡូគស តំណាងឱ្យលោក ផធឡស្ថិតក្នុង កំណត់ច្បាប់ គប្បីលើកយកមក ពិចារណា ។

សាលដីការបស់សាលាឧទ្ធរណ៍ដែលសម្រេចសេក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ

សូមក្រុមប្រឹក្សា ជំនុំជំរះ សំរេចតាមច្បាប់ ។

ឈ្មោះ សយបានឆ្លើយថាៈ ចំនួនទឹកប្រាក់ដែលបានផ្ញើក្នុងធនាគារនៅថ្ងៃទី០៥-០៥-៩៧មានចំនួន ដប់ម៉ឺន ដុល្លាអាមេរិក និង នៅថ្ងៃទី០៧-០៥-៩៧ បានដាក់ចំនួនម្ភៃម៉ឺនដុល្លាអាមេរិក ទៀត ដូច្នេះ សរុបទឹកប្រាក់ទាំងអស់មាន ចំនួន សាមសិបម៉ឺនដុល្លាអាមេរិក តែគាត់បានដកជាបន្តបន្ទាប់ដោយនៅសល់ ប្រាក់តែ ម្ភៃម៉ឺន មួយពាន់ ប្រាំរយ សាមសិបបួន និង ចិតសិបសេន ( ២០.១៥៣.៤៧០ដុល្លា) និង ការប្រាក់ ដប់មួយភាគរយក្នុងមួយឆ្នាំ ទៀត តែសព្វថ្ងៃ ធនាគារនេះបានក្ស័យធនបាត់ទៅហើយៗសំណង់អាគារពីរជាន់របស់ធនាគារបានដាក់បញ្ចាំនៅធនាគារជាតិ ។

ដូច្នេះ សូមឯឧត្តម មេត្តាសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រុមរបាយការណ៍

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់ដើមចោទ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថាៈ បណ្តឹងសាទុក្ខលេខៈ ២៣៣ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ របស់លោក ផធឡធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមក ជំនុំជំរះ បានដោយយោងតាម មាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី។

យល់ឃើញថាៈ លោក ផធឡដែលជាប្រធានធនាគារសន្តិភាពពាណិជ្ជចំកាត់ បាន ទទួលស្គាល់នៅក្នុងកំណត់ហេតុផ្សះផ្សាសំរុះសំរួលចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០០ និងក្នុងកំណត់ហេតុយក ចម្លើយចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០០ ថាធនាគារពិតជានៅជំពាក់ប្រាក លោក គសសវចំនួន ២០.១៥៣.៤៧០ដុល្លាអាមេរិក និង ការប្រាក់១១% ក្នុងមួយឆ្នាំ គិតពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០០ រហូតមកពិតប្រាកដមែន ។ ដូច្នេះធនាគារស្តិភាពពាណិជ្ជាចំកាត់ មានកាតព្វកិច្ចសងប្រាក់ដែលខ្លួននៅជំពាក់ លោក គសសវ នេះទៅឱ្យលោក គសសវ វិញ ដោយយោងតាមមាត្រា២០ នៃក្រឹត្យ-ច្បាប់ លេខៈ៣៨ ក្រចស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅតិច្ចសន្យា ។

យល់ឃើញថាៈ តាមលិខិតបង្គាប់ឱ្យធ្វើសារណាលោកមេភូមិ មណ្ឌល១ ឈ្មោះ ជម បាន បញ្ជាក់ថាឈ្មោះ ផធឡ អត់នៅ រកពុំឃើញ ដូច្នេះការពន្យាពេលសវនាការតទៅទៀតនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៏របស់ដើមចោទ ។

យល់ឃើញថាៈ សាលដីការជ្ជប្បវេណីលេខ ១៥៤ (ឈ) ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ របស់ សាលាឧទ្ធរណ៏ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខ ២៣៣ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ របស់លោក ផធឡជាប្រធានសាខាធនាគារសន្តិភាពពាណិជ្ជាចំកាត់ ទុកជាត្រឹមត្រូវតាមទម្រង់ ច្បាប់ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីការជ្ជប្បវេណីលេខ ១៥៤(ឈ)ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០១ របស់ សាលាឧទ្ធរណ៏ទុកជាបានការពេញទាំងមូល ។

៣ - រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលលោក គសសវបានបង់ទុកនៅតុលាការកពូល គឺៈ

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុបចំនួន ១៩.០០០៛ រួចតម្រូវ ឱ្យលោកផធឡសងប្រាក់ចំនួន ១៩០០០៛ ទៅលោក គសសវ វិញ ។

បង្គាប់ឱ្យសាខាធនាគារសន្តិភាពពាណិជ្ជចំកាត់ដែលមានលោក ផធឡជាប្រធាន បង់ពន្ធសមាមាត្រ មួយភាគរយ លើចំនួនទឹកប្រាក់ដែលត្រូវសង ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៤ ។